ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្ដីពី

# ការផ្ដន្ទាទោសអំពើភេរវកម្ម

សេវាកម្មមេធាវីកម្ពុជា

រចនាគម្របដោយ អ៊ូ វឌ្ឍនៈ ជំនួយការមេធាវី នៅសេវាកម្មមេធាវីកម្ពុជា

# ច្បាប់

# ស្តីពី

# ការផ្តន្ទាទោសអំពើភេរវកម្ម

រដ្ឋកម្ពុជា

រដ្ឋសភា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ច្បាប់

ស្តីពី

ការផ្តន្ទាទោសអំពើភេរវកម្ម

មាត្រា ១ .- អំពើភេរវកម្ម ជាអំពើហឹង្សាទាំងឡាយ ដែលប្រព្រឹត្តដោយជនម្នាក់ ឬ ជនមួយក្រុម ឬ ច្រើនក្រុម បង្កើតភាពភិតភ័យពាស់ពេញក្នុងចំណោមប្រជាជន ក្នុងគោលដៅធ្វើអោយជ្រួលច្របល់យ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ និង អោយប៉ះពាល់ដល់ស្ថេរភាពនយោបាយ ។

មាត្រា ២ .- ជនណាចាប់ពង្រត់មនុស្ស ឬ បង្ខាំងមនុស្សដោយខុសច្បាប់ ក្នុងគោលដៅធ្វើវិច្ឆេទកម្ម ទារយកប្រាក់ សងសឹក ធ្វើជាចំណាប់ខ្មាំង យកទៅលក់ និង ជនណាដែលប្រព្រឹត្តអំពើភេរវកម្មផ្សេងៗ ទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ ឆ្នាំ ដល់ ២០ ឆ្នាំ ។

ប្រសិនបើការចាប់ពង្រត់ បង្ខាំងមនុស្សដោយខុសច្បាប់ ឬ អំពើភេរវកម្មនោះធ្វើទៅលើអនីតិជន ឬ បណ្តាលអោយជនរងគ្រោះស្លាប់ ជនប្រព្រឹត្តល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ដោយឥតគិតពីស្ថានទោសប្រណីទោស ។

មាត្រា ៣ .- ជនណាដែលប៉ុនប៉ងសម្លាប់មនុស្ស ឬ សម្លាប់មនុស្សដោយចេតនាគិតទុកជាមុនក្នុងគោលដៅធ្វើភេរវកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ដោយឥតគិតពីស្ថានទោសប្រណីទោស ។

មាត្រា ៤ .- ច្បាប់នេះត្រូវបានប្រកាសជាប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃរដ្ឋកម្ពុជា អនុម័តនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩២ នាសម័យប្រជុំលើកទី ២២ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩២

ចេញផ្សាយ 10 ចុះ 7/2/92

ជ. រដ្ឋសភា

ប្រធាន

ហត្ថលេខា និង ត្រា ជា ស៊ីម

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

អគ្គលេខាធិការ ក្រុមប្រឹក្សារដ្ឋ

ហត្ថលេខា និង ត្រា : ចាន់ វ៉េន